Kids of Destiny®
Reaching the Next Generation



www.kidsofdestiny.org

# ៣.០៣ កសិករដែលព្រោះគ្រាប់ពូជខ្លះៗ លូកា ៨:៤-១៥

មានក្រុមមនុស្សធំៗដទៃទៀត បានស្តាប់ព្រះយេស៊ូវបង្រៀននៅថ្ងៃនេះ ។ ព្រះយេស៊ូវទ្រង់កំពុងតែប្រាប់រឿងរ៉ាវទាំងឡាយដល់ពួកគេដូច្នេះពួកគេត្រូវតែរៀនតាមមធ្យោបាយល្អៗក្នុងការរស់នៅ។តាមការនិយាយ ប្រាប់នូវរឿងរ៉ាវរបស់ផងទ្រង់ ពួកគេត្រូវតែមានលទ្ធភាព ដែលងាយស្រួលក្នុងការយល់ដឹងនូវមេរៀនទាំងឡាយ ដែលទ្រង់បានព្យាយាមបង្រៀនដល់ពួកគេ ។

នៅថ្ងៃមួយនោះ ព្រះយេស៊ូវទ្រង់កំពុងតែបានមានបន្ទូលប្រាប់នូវរឿងមួយ អំពីកសិករដែលកំពុងតែបានព្រោះគ្រាប់ពូជរបស់គាត់ ។ កសិករនោះបានចាប់យកគ្រាប់ពូជខ្លះ នៅក្នុងដៃរបស់គាត់ ហើយក៏បានព្រោះដោយថ្នមៗ នៅជុំវិញដីរបស់គាត់ដើម្បីឲ្យគ្រាប់ពូជនោះបានដុះឡើង ។ គាត់មានសង្ឃឹមថា គ្រាប់ពូជនោះនឹងអាចលូតលាស់ឡើង បានទៅភោគផលសម្រាប់ក្រុមគ្រួសាររបស់គាត់ ។ គ្រាប់ពូជនោះក៏បានធ្លាក់ទៅលើប្រភេទដីផ្សេងៗ សម្រាប់ជាផលប្រយោជន៍របស់កសិករនោះ ។

គ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ ។ គ្រាប់ពូជទាំងនោះ ត្រូវបានធ្វើឲ្យខ្ទេចខ្ទីដោយសត្វពាហណៈឬដោយមនុស្សដើរជាន់ ។ សត្វហើរលើអាកាសក៏បានចឹកស៊ីគ្រាប់ពូជទាំងនោះអស់ ។ នោះគឺបានទៅជាចំណីដ៏ល្អរបស់សត្វបក្សាបក្សីទាំងឡាយ! យ៉ាងណាក៏ដោយ គ្រាប់ពូជទាំងអស់នោះ មិនត្រូវបានដុះលូតលាស់ឡើយ ។

គ្រាប់ពូជខ្លះ បានធ្លាក់ទៅលើដីថ្ម ដែលហៅថា ថ្មគ្រួស ដែលបង្កើតឡើងដោយដីខ្លះ ។ គ្រាប់ពូជទាំងនោះ ក៏បានចាប់ដុះឡើង ប៉ុន្តែ ដោយគ្មានដីច្រើន ធ្វើឲ្យគ្រាប់ពូជទាំងនោះ មិនលូតលាស់តទៅទៀតបាន ដោយឫសមិនអាចចាក់ចូលជ្រៅទៅក្នុងដីបាន។ ដីគ្រួសថ្មគឺដូចជាធ្លាក់ទៅលើផ្លូវ ។ គ្រាប់ពូជដទៃទៀត បានធ្លាក់ទៅលើបន្លា ។ បន្លាទាំងនោះអាចមានកម្លាំងខ្លាំងណាស់ ។ សូម្បីតែគ្រាប់ពូជព្យាយាមលូតលាស់យ៉ាងណាក៏ដោយ ក៏បន្លាបានរួបរឹតពួកគេ កាន់តែខ្លាំងឡើងដែរ ។

នៅទីបំផុត មានគ្រាប់ពូជដែលបានធ្លាក់ទៅលើដីល្អ ។ គ្រាប់ពូជទាំងនោះ ក៏បានលូតលាស់ឡើង មានសុខភាពសុខភាពល្អ និងមានកម្លាំង ។ គ្រាប់ពូជទាំងនោះក៏បាន ត្រឡប់ទៅជាគ្រាប់ពូជដ៏ល្អ រហូតដល់កសិករអាចទទួលផលចម្រូតបាន ។ ពួកសិស្សបានទូលសូមដល់ព្រះយេស៊ូវ ឲ្យពន្យល់ពីរឿងនោះដល់ពួកគេ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលឆ្លើយថា «រឿងរ៉ាវនេះ គឺនិយាយអំពីមនុស្ស ដែលបានឮព្រះបន្ទូលរបស់ព្រះ ។ គ្រាប់ពូជដែលធ្លាក់ទៅលើផ្លូវ គឺជាមនុស្សដែលបានស្តាប់ឮព្រះបន្ទូលរបស់ព្រះ ប៉ុន្តែមិនបានចាក់ចូលទៅក្នុងចិត្តទេ ក៏មានអ្នកចូលមកលួចយកព្រះបន្ទូលចេញពីពួកគេទៅបាត់ ។ សាតាំងបានមកលួចយកអ្វីដែលល្អទៅបាត់ ។ វាមិនចង់ឲ្យមនុស្សស្តាប់តាមព្រះ ។ វាលួចព្រះបន្ទូលរបស់ព្រះ ចេញពីចិត្តរបស់មនុស្ស ដូច្នេះ ពួកគេនឹងមិនជឿ និងមិនបានទទួលសេចក្តីសង្គ្រោះឡើយ» ។

«គ្រាប់ពូជដែលធ្លាក់ទៅលើថ្ម គឺជាមនុស្សដែលបានស្តាប់ព្រះបន្ទូលរបស់ព្រះ ក៏បានទទួលដោយអំណរ ប៉ុន្តែ បន្ទាប់មកទៀត ពួកគេក៏បាត់បង់នូវការចាប់អារម្មណ៍ ។ បន្ទាប់មកទៀត ពួកគេក៏មានបញ្ហា ពួកគេភ្លេចអស់នូវការទទួលដោយអំណរ ក៏លែងមានការរំភើប ក្នុងការរៀនអំពីព្រះ» ។ «បន្ទាប់មក ក៏មានគ្រាប់ពូជដែលធ្លាក់ទៅលើបន្លា ។ គ្រាប់ពូជទាំងនោះ គឺជាមនុស្សដែលបានស្តាប់ព្រះបន្ទូលរបស់ព្រះ ប៉ុន្តែ មិនយូរប៉ុន្មាន ពួកគេក៏ចាប់ទទួលនូវការរវល់ ជាមួយនឹងការងារប្រចាំថ្ងៃរបស់ពួកគេដើម្បីធ្វើ ដើម្បីរកលុយ-របស់របរផ្សេងៗ ពួកគេបានរៀន តែបានទទួលការចាក់ចេញទៅតាមចិត្តគំនិតផ្ទាល់របស់ពួកគេ» ។

«គ្រាប់ពូជដែលសាបព្រោះធ្លាក់ទៅលើដីល្អ គឺជាមនុស្សដែលបានស្តាប់ព្រះបន្ទូលរបស់ព្រះ ហើយបានសម្រេចចិត្ត ធ្វើនូវអ្វីដែលព្រះទ្រង់មានបន្ទូលប្រាប់ពួកគេ ឲ្យធ្វើ-មិនមានបញ្ហាអ្វីឡើយ-ហើយនឹងមានការលូតលាស់ជាច្រើន ។ នឹងបានជាគ្រាប់ពូជដ៏ល្អសម្រាប់អស់អ្នកណា ដែលស្រឡាញ់ និងបម្រើព្រះ» ។

នៅពេលដែលយើងស្តាប់ឮ នូវព្រះបន្ទូលរបស់ព្រះ យើងត្រូវការស្តាប់ដោយប្រុងប្រយ័ត្ន ។ យើងត្រូវការគិតអំពីរបៀបដែលយើងអាចរៀនពីការស្តាប់ឮ និងចាប់ផ្តើមធ្វើសកម្មភាព តាមមធ្យោបាយ ដែលព្រះទ្រង់សព្វព្រះហឫទ័យចង់ឲ្យយើងធ្វើសកម្មភាព ។ យើងអាចបានដូចជាគ្រាប់ពូជ ដែលបានសាបព្រោះទៅលើដីល្អអញ្ចឹង ។ យើងអាចដឹកនាំមនុស្សដទៃទៀត ឲ្យបានស្គាល់ព្រះ និងសេចក្តីសប្បុរសរបស់ព្រះអង្គ ។

# ៣០៣ កសិករដែលព្រោះគ្រាប់ពូជខ្លះៗ-ការណែនាំរបស់គ្រូបង្រៀន
# លូកា ៨:៤-១៥

Kids of Destiny®
Reaching the Next Generation

## កំណត់សម្គាល់៖

1) ព្រះយេស៊ូវទ្រង់មានរឿងមួយ ប្រាប់ដល់ហ្វូងមនុស្សដែលកំពុងតែស្តាប់ព្រះអង្គ ។ រឿងនេះគឺបាននិយាយអំពីកសិករដែលព្រោះគ្រាប់ពូជ ។
2) គ្រាប់ពូជដែលបានធ្លាក់ទៅលើផ្លូវ ត្រូវបានមនុស្សកម្ទេច និងសត្វដើរជាន់ ។ សត្វស្លាបបានឃើញ និងចឹកស៊ី ។
3) គ្រាប់ពូជដែលបានធ្លាក់ទៅលើដីថ្ម គឺមិនមានការលូតលាស់បានល្អទេ ពីព្រោះមិនបានចាក់ឫសទៅក្នុងដីបានគ្រាប់គ្រាន់ ។
4) គ្រាប់ពូជដែលបានធ្លាក់ក្នុងបន្លា បន្លាក៏បានខ្ទប់ជិត ពីព្រោះបន្លាមានកម្លាំងខ្លាំងដែលព័ទ្ធ ជុំវិញគ្រាប់ពូជទាំងនោះ ។
5) គ្រាប់ពូជដែលបានធ្លាក់ទៅលើដីល្អ គឺបានលូតលាស់ មានសុខភាពល្អ និងមានកម្លាំង ។ វាមានផលល្អចេញពីគ្រាប់ពូជទាំងនេះ ។
6) យើងចង់បានដូចជាដី ដែលមានគ្រាប់ពូជ ដែលបង្កើតផលបានល្អ ។ យើងត្រូវការស្តាប់ព្រះបន្ទូលរបស់ព្រះ និងស្តាប់បង្គាប់តាមព្រះបន្ទូលព្រះអង្គ ។ បន្ទាប់មក យើងនឹងមានលទ្ធភាពប្រាប់ ដល់អ្នកដទៃទៀតអំពីព្រះ ។

## សំណួរ៖

1) តើព្រះយេស៊ូវទ្រង់កំពុងតែបានប្រាប់រឿងអ្វី ដល់ប្រជាជន?
2) តើមានការអ្វីកើតឡើង ចំពោះគ្រាប់ពូជដែលធ្លាក់ទៅតាមផ្លូវ?
3) តើមានការអ្វីកើតឡើង ចំពោះគ្រាប់ពូជដែលធ្លាក់ទៅលើថ្ម?
4) តើមានការអ្វីកើតឡើង ចំពោះគ្រាប់ពូជដែលធ្លាក់ទៅក្នុងបន្លា?
5) តើមានការអ្វីកើតឡើង ចំពោះគ្រាប់ពូជដែលធ្លាក់ទៅលើដីល្អ?
6) តើមានការអ្វីកើតឡើង ចំពោះយើងនៅពេលដែលស្តាប់ព្រះបន្ទូលរបស់ព្រះ និងស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះអង្គ?

## ចម្លើយ៖

1) ព្រះយេស៊ូវទ្រង់បានប្រាប់រឿងកសិករ ដែលបានព្រោះគ្រាប់ពូជខ្លះៗ ។
2) គ្រាប់ពូជទាំងឡាយដែលបានធ្លាក់ទៅលើផ្លូវ ត្រូវបានគេដើរជាន់ ហើយសត្វស្លាបមកចឹកស៊ី ។
3) គ្រាប់ពូជទាំងឡាយមិនអាចលូតលាស់បានល្អ នៅក្នុងដីដែលមានថ្មឡើយ ពីព្រោះឫសមិនអាចចូលជ្រៅទៅក្នុងដីបាន ។
4) គ្រាប់ពូជទាំងឡាយដែលបានធ្លាក់ទៅលើបន្លា ដែលទទួលបាននូវការរួបរឹត ដូច្នេះ គ្រាប់ពូជទាំងនោះ មិនអាចលូតលាស់បានឡើយ ។
5) គ្រាប់ពូជទាំងឡាយដែលបានធ្លាក់ទៅលើដីល្អ គឺបានលូតលាស់ មានសុខភាពល្អ និងមានកម្លាំង ។ គ្រាប់ពូជទាំងនោះបានទទួលផលចម្រើនជាច្រើនឡើង ។
6) នៅពេលដែលយើងស្តាប់ព្រះបន្ទូលរបស់ព្រះ ហើយស្តាប់បង្គាប់ដល់ព្រះអង្គ នោះយើងនឹងបានដូចជាគ្រាប់ពូជ ដែលបង្កើតផលបានល្អបរិបូរឡើង ។ បន្ទាប់មក យើងនឹងមានលទ្ធភាពដើម្បីប្រាប់ដល់អ្នកដទៃទៀតអំពីព្រះ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org